**BMI0069**

# សម្ភាសន៍ជាមួយឈ្មោះ ប៊ុន សារិន ភេទប្រុស អាយុ៦១ឆ្នាំ
មុខងារជំនាន់ខ្មែរក្រហមមានតួនាទីៈ «យោធា»
មុខងារបច្ចុប្បន្នៈ «កសិករ»
ស្រុកកំណើតនៅភូមិដារ ឃុំដារ ស្រុកមេមត់ ខេត្តកំពង់ចាម
រស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០
សម្ភាសន៍ដោយៈ សុខ វណ្ណៈ
០០:៥៤:៣៩
២៣ទំព័រ

វណ្ណៈ ៈ ចឹងមុនហ្នឹងខ្ញុំចាប់ផ្ដើមសម្ភាសន៍អ៊ំ ខ្ញុំសូមណែនាំខ្លួនថាខ្ញុំមកពីខាងណា ។

សារិន ៈ បាទ ។

វណ្ណៈ ៈ ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំឈ្មោះសុខ វណ្ណៈ ។

សារិន ៈ បាទ ។

វណ្ណៈ ៈ ហើយខ្ញុំបានមកដល់ស្រុកម៉ាឡៃនេះ គឺចង់ដឹងរឿងរ៉ាវប្រវត្តិនៅម៉ាឡៃយើងនេះ ដើម្បីយកទៅសរសេរជាសៀវភៅដើម្បីឲ្យក្មេងជំនាន់ក្រោយហ្នឹងបានដឹងថា ម៉ាឡៃពីមុនយ៉ាងម៉េច ហើយម៉ាឡៃសម័យនេះមានការខុសប្លែកគ្នាយ៉ាងម៉េច?

សារិន ៈ បាទ ។

វណ្ណៈ ៈ ចឹងបទសម្ភាសន៍ខ្ញុំជាមួយអ៊ំហ្នឹងអាចឲ្យខ្ញុំយកទៅសរសេរជាសៀវភៅទុកជាប្រវត្តិសាស្ត្របានទេ?

សារិន ៈ បាទ ។

វណ្ណៈ ៈ ចឹងខ្ញុំមានសម្ភាសន៍និងថតរូបខ្លះ?

សារិន ៈ បាទ ។

វណ្ណៈ ៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំឈ្មោះអីដែរ?

សារិន ៈ ប៊ុន សារិន ។

វណ្ណៈ ៈ ចឹងអ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

សារិន ៈ ខ្ញុំកើតនៅឆ្នាំ១៩៤៩ ។

វណ្ណៈ ៖ ចឹងប្រពន្ធឈ្មោះអីដែរ?

សារិន ៖ ប្រពន្ធឈ្មោះ ជា ស៊ីម ។

វណ្ណៈ ៖ ចឹងអាយុគាត់ប្រហែលជាប៉ុន្មានដែរ ។

សារិន ៖ អាយុ៥៥ ។

វណ្ណៈ ៖ មានកូនចៅប៉ុន្មាននាក់?

សារិន ៖ មានកូន៥នាក់ ។

វណ្ណៈ ៖ ស្រីទាំងអស់?

សារិន ៖ ស្រីបីនាក់ ។

វណ្ណៈ ៖ ឪពុករបស់អ៊ំឈ្មោះអី?

សានិរ ៖ ឪពុកខ្ញុំឈ្មោះសៀក ។

វណ្ណៈ ៖ ត្រកូលគាត់?

សារិន ៖ ត្រកូលគាត់គា ប៉ុនហ្នឹង ប៉ុន សៀក ។

វណ្ណៈ ៖ ចុះម្ដាយឈ្មោះអីដែរ?

សារិន ៖ ម្ដាយឈ្មោះម៉ៅ ។

វណ្ណៈ ៖ មានដឹងត្រកូលទេ?

សារិន ៖ អត់ទេ ។

វណ្ណៈ ៖ ចឹងគាត់ទាំងពីរសព្វថ្ងៃនៅរស់ឬមួយស្លាប់បាត់ហើយ?

សារិន ៖ ស្លាប់បាត់ហើយ ។

វណ្ណៈ ៖ ចឹងគាត់ស្លាប់នៅពេលណាដែរ?

សារិន ៖ ម្ដាយខ្ញុំស្លាប់នៅឆ្នាំ១៩៧២ ។

វណ្ណៈ ៖ ចឹងស្លាប់កាលជំនាន់សង្គ្រាម?

សារិន ៖ បាទ ។

វណ្ណៈ ៖ ចុះឪពុក?

សារិន ៖ ឪពុកស្លាប់នៅឆ្នាំ៨០ ។

វណ្ណៈ ៖ ចឹងគាត់ស្លាប់ដោយជំងឺ?

សារិន ៖ បាទ!ជំងឺគាត់ ។

វណ្ណៈ ៖ ចឹងបងប្អូនបង្កើតមានប៉ុន្មាននាក់?

សារិន ៖ បងប្អូនបង្កើតមាន៥នាក់ ។

វណ្ណៈ ៖ រាល់ថ្ងៃនេះនៅសល់ប៉ុន្មាននាក់?

សារិន ៖រាល់ថ្ងៃនេះនៅសល់បួននាក់ ។

វណ្ណៈ ៖ ចឹងស្លាប់មួយទេ?

សារិន ៖ បាទ!ស្លាប់មួយត្រូវគ្រាប់កាលទម្លាក់គ្រាប់បែកកាលឆ្នាំអាមេរិចកាំងធ្វើសង្គ្រាមនោះណាស់ ។

វណ្ណៈ ៖ បាទៗ ១កាលឆ្នាំ៧២ - ៧៣ ?

សារិនៈ ៖បាទ ។

វណ្ណៈ ៖ ចឹងស្រុកកំណើត?

សារិន ៖ ស្រុកកំណើតនៅភូមិដា ។

វណ្ណៈ ៖ ឃុំ?

សារិន ៖ ឃុំដាដែរ ។

វណ្ណៈ ៖ ខេត្ត?

សារិន ៖ ស្រុកមេមុត ខេត្តកំពង់ចាម ។

វណ្ណៈ ៖ ឥឡូវនៅភូមិអី?

សារិន ៖ ឥឡូវនៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ ៖ ចឹងខ្ញុំចង់អីរៀបរាប់ថារឿងរ៉ាវដែលកើតឡើងចំពោះអ៊ីផ្ទាល់ឬអ៊ីរៀនសូត្របានដល់ណា រៀននៅសាលាណានៅពេលឈប់រៀនអ៊ីចេញទៅធ្វើអីនៅខាងណា?

សារិន ៖ កាលនៅក្មេងនោះខ្ញុំរៀនបានត្រឹមថ្នាក់ទី៧«ចាស» រៀននៅសាលាវត្តភូមិខ្ញុំហ្នឹង ។

វណ្ណៈ ៖ នៅសាលាភូមិដា?

សារិន ៖ នៅសាលាវត្តតែម្តង ។

វណ្ណៈ ៖ វត្តហ្នឹងគេហៅវត្តអី?

សារិន ៖ វត្តដាចឹងតែម្តង ។

វណ្ណៈ ៖ ចឹងយ៉ាងម៉េចទៀត?

សារិន ៖ ដល់បន្ទាប់មកដល់រៀនៗទៅដល់ឆ្នាំ៧០ហ្នឹងកើតមានរដ្ឋប្រហាក៏ឈប់រៀន ។

វណ្ណៈ៖ បាទ ។

សារិន ៖ ឈប់រៀនមកជួយធ្វើស្រែចំការជាមួយឪពុកម្តាយខ្លះទៅកាលនោះ ដល់ក្រោយមកទៀតថាមានរណៈសិរ្សរំដោះជាតិក៏ចូលធ្វើហ្នឹងទេទៅ ។

វណ្ណៈ ៖ នៅឆ្នាំណា?

សារិន ៖ កាលហ្នឹងនៅឆ្នាំ៧២ ។

វណ្ណៈ ៖ ចូលទៅខាងណាវិញ?

សារិន ៖ ចូលទៅខាងរណៈសិរ្សរំដោះជាតិកាលនោះខ្ញុំចូលទៅជាមួយគេទៅ ទៅវៃជាពួកធៀវគឺកាលនោះ ។

វណ្ណៈ ៖ កាលហ្នឹងវៃជាមួយទាហានលន់ នល់?

សារិន ៖ វៃជាមួយទាហានលន់ នល់ ។

វណ្ណៈ ៖ កាលហ្នឹងចូលជាមួយកងពលពីណាគេ?

សារិន ៖ កាលហ្នឹងខ្ញុំនៅតំបន់២១ ។

វណ្ណៈ ៖ តំបន់២១ភូមិភាគអីគេ?

សារិន ៖ ភូមិភាគបូព៌ា ។

វណ្ណៈ ៖ ចឹងនៅភូមិភាគបូព៌ាចឹងមានសោភឹមដឹកនាំ?

សារិន ៖ បាទ!ហ្នឹងហើយសោភឹម កាលហ្នឹងមិនដឹងជាសោភឹមអីទេ កាលហ្នឹងគេឲ្យទៅណាទៅហ្នឹងហើយ ។

វណ្ណៈ ៖ នៅបូព៌ាតាសោភឹមគាត់កាន់កាប់?

សារិន ៖ បាទ ។

វណ្ណៈ ៖ ចឹងពូមិនដែលស្គាល់សោភឹមទេ?

សារិន ៖ មិនដែលស្គាល់ផង កាលហ្នឹងតូចតាចពុំតែឈ្មោះគេថា ធ្វើតែតាមគេទៅ ។

វណ្ណៈ ៖ ចឹងក្រោយមកទៀតយ៉ាងម៉េចដែរ?

សារិន ៖ ក្រោយមកទៀតនៅឆ្នាំ៧៥ និយាយឆ្នាំ៧៥តែម្តងទៅណាស់ ។

វណ្ណៈ ៖ បាទ ។

សារិន ៖ ៧៥ហ្នឹងរំដោះហើយបានគេឲ្យមកនៅភ្នំពេញនៅក្រសួងដឹកជញ្ជូនជើងទឹកណាស់ ។

វណ្ណៈ៖ នៅក្រសួង?

សារិន ៖ ក្រសួងដឹកជញ្ជូនជើងទឹក ។

វណ្ណៈ ៖ ជើងទឹកនៅណា?

សារិន ៖ នៅព្រែកព្នៅជិតច្រាំងចំរេះហ្នឹង ។

វណ្ណៈ ៖ ចឹងនៅពេលដែលគេចាប់ខ្លួនសោភឹមនៅខាងពូយ៉ាងម៉េចដែរ?

សារិន ៖ កាលគេចាប់ហ្នឹងខ្ញុំនៅភ្នំពេញខ្ញុំមិនបានដឹងដែរ ។

វណ្ណៈ ៖ ចឹងតាំងពីពូចូលធ្វើបដិវត្តរហូតមកតាំងពី៧០ដល់៧៥ពូមានបានឡើងប្រធានវរៈអីហ្នឹងគេទេ?

សារិន ៖ អត់ផង ។

វណ្ណៈៈ ចឹងអត់ទេ?

សារិន : បាទ ។

វណ្ណៈ : ចឹងកាលពូមកនៅជើងទឹកហ្នឹងពីណាគេជាអ្នកដឹកនាំ?

សារិន : គណៈក្រសួងហ្នឹងឃើញកាលនោះអាម៉ននិងពីណាពីណីខ្លះទេពូថាតា ម៉នៗ ។

វណ្ណៈៈ ប្រធានជើងទឹក?

សារិន : បាទ!ដល់ក្រោយបាត់ទៅមិនដឹងជាពីណាផ្សេងទៀត កាលហ្នឹងខ្ញុំមិនសូវស្គាល់ច្បាស់ដែរ ។

វណ្ណៈ : ចឹងកាលហ្នឹងទាហានជើងទឹកមានគ្នាប៉ុន្មាននាក់ទៅ?

សារិន : មិនមែនជាទាហានទេ នៅក្រសួងជើងទឹក ។

វណ្ណៈៈ ចឹងលែងជាទាហានហើយកាលហ្នឹង?

សារិន : កាលហ្នឹងគេឲ្យធ្វើទូកអីទៅ ។

វណ្ណៈ : ចឹងកាលហ្នឹងមានគ្នាប៉ុន្មាននាក់?

សារិន : ច្រើនណាស់រាប់រយនាក់ ច្រើនណាស់មួយក្រសួងហ្នឹងមិនដឹងជាប៉ុន្មានដែរ ។

វណ្ណៈៈ ធ្វើទូកចឹង?

សារិន : បាទ ។

វណ្ណៈ : ចឹងធ្វើទូកដឹកអីទេ?

សារិន : ធ្វើទូកធ្វើកាណូត រឿងដឹករបស់គេយើងអ្នកធ្វើឲ្យគេ ។

វណ្ណៈៈ ចឹងអ្នកដឹកសម្ភារផ្សេងទៀត?

សារិន : បាទ ។

វណ្ណៈ : ចឹងតាំងពីឆ្នាំ៧៥ដល់ឆ្នាំ៧៩ គេមានផ្លាស់ផ្ដូពូទៅខាងណាទៀតទេ?

សារិន : អត់ទេ ដល់យួនវៃមករត់មកបណ្ដោយ ។

វណ្ណៈៈ ចឹង?

សារិន : ខ្ញុំរត់ចេញពីភ្នំពេញមក ។

វណ្ណៈៈ ចឹងកាលសម័យពូរស់នៅព្រែកព្នៅចឹង?

សារិនៈ បាទ ។

វណ្ណៈ : ចឹងនៅក្នុងអំឡុងពេលហ្នឹង ពូមានដឹងថាមានគេចាប់កម្មាភិបាលខ្មែរក្រហមអីទេ?

សារិន : ខ្ញុំកាលហ្នឹងនៅតូចតាចមិនបានដឹងទេ ។

វណ្ណៈ : ចឹងនៅកន្លែងពូមានបាត់ខ្លួនទេ?

សារិន : នៅកន្លែងខ្ញុំមិនពូខ្ញុំថាទេ បាត់ប្រធានស្រួងហ្នឹងមួយទៀតទៅបានឃើញមកថ្មីមួយទៀត ។

វណ្ណៈ    បាទ ។

សារិន  :  បើគេចាប់ខ្ញុំមិនបានដឹងដែរ ។

វណ្ណៈ  :  ចឹងកាលហ្នឹងពូមានសំណាងដែរ ពីព្រោះថានៅពេលដែលគេចាប់សោភឹមទៅខាងបូព៌ាកូនទាហានបូព៌ាគេបន្តស្រាវជ្រាវចាប់យកទៅច្រើនណាស់?

សារិន  :  បាទៗ ។

វណ្ណៈ    ហ្នឹងហើយពដូចចាសំណាងដែលបានរួចខ្លួនចឹង?

សារិន  :  បាទ ។

វណ្ណៈ    ព្រោះពួកនិរតីចូលមកអីគេធ្វើបាបបូព៌ាហ្នឹង?

សារិន  :  កាលហ្នឹងមានខាងនិរតីដេញតាមវ៉ៃតាមកាប់ តែពួកយើងចេះតែគេចដូចជាសំណាងខ្ញុំដែលហ្នឹងណាស់ ។

វណ្ណៈ  :  បាទ ។

សារិន  :  កាលហ្នឹងឲ្យតែឬបូព៌ាគេកំទេចចោលហើយ ។

វណ្ណៈ  :  ចឹងកាលឆ្នាំ៧៩ហេតុអីបានជាពូមិនរត់ទៅស្រុកកំណើតបែរជារត់ទៅជាយដែនវិញ?

សារិន  :  ទៅអត់រួចទន្លេវាពីរជាន់អត់មានអីហែលរួច ។

វណ្ណៈ  :  ចឹងកាលហ្នឹងអត់មានខ្លាចយួនពីទេ?

សារិន  :  អត់មានទេខ្លាចទេ នឹកឃើញពីរនាក់ប្រពន្ធប្រុងទៅដែលតែទន្លេពីរជាន់ទៅវាមិនរួច ចុះដៃទន្លេសាបហ្នឹងមួយទន្លេស្ពានជ្រោយចង្វារនិងទន្លេមេគង្គហ្នឹងហែលម៉េចរួច ។

វណ្ណៈ  :  ចុះមិនគិតដើរតាមផ្លូវ?

សារិន  :  ដើរតាមផ្លូវណាបើគេផ្ដាច់ស្ពានអស់ហើយហ្នឹង កាលហ្នឹងស្ពានជ្រោយចង្វារដាច់ហើយ ។

វណ្ណៈ  :  បាទ ។

សារិន  :  មិនដឹងដាច់តាំងពីឆ្នាំណាដែរកាលហ្នឹងខ្ញុំចង់តែប្របួលប្រពន្ធទៅស្រុកដែលហ្នឹងតែទៅមិនរួចទៅខ្លាចរឿងទឹកទេរឿងវ៉ៃគ្នាមិនអីទេ មិនឆាយគេសម្លាប់យើងទេ ព្រោះយើងភាសខ្លួន ។

វណ្ណៈ  :  ចឹងកាលហ្នឹងពូរៀបការនៅឆ្នាំណា?

សារិន  :  កាលហ្នឹងមើលកាលហ្នឹងគេរៀបឲ្យខ្ញុំ ។

វណ្ណៈ    បាទ ។

សារិន  :  កាលហ្នឹងនៅឆ្នាំ៧៧-៧៨ហ្នឹង ៧៨ ។

វណ្ណៈ  :  រៀបប៉ុន្មានគូរ?

សារិន  :  រៀប៣គូរ មានតែបីគូរទេ ខ្ញុំអាវ៉េតនិងអាផោ ។

វណ្ណៈ : ចឹងអ្នកដែលបានរៀបការជាមួយពូឥឡូវគេនៅហ្នឹងដែរ?

សារិន : អត់ទេខ្វះទៅអាមេរិចទៅ អីខ្វះអស់ ។

វណ្ណៈ : ចឹងកាលពូរៀបការហើយដល់ឆ្នាំ៧៩ពូមានកូនហើយនៅ?

សារិន : នៅ ។

វណ្ណៈ : ចឹងពេលរត់ហ្នឹងមិនទាន់មានដែរ?

សារិន : ពេលហ្នឹងបើមានប្រហែលជាមិនរស់ទេកូន ។

វណ្ណៈ : ម៉េចចឹង?

សារិន : វាវេទនាណាស់ពេលរត់ចូលក្នុងព្រៃនោះ ឡើងភ្នំផងអីផង ។

វណ្ណៈ : ចឹងពូរត់ចេញពីភ្នំពេញមកតាមផ្លូវណា?

សារិន : ចេញពីភ្នំពេញមកតាមផ្លូវជាតិលេខ៥ហ្នឹង កាលហ្នឹងមកដល់កំពង់ឆ្នាំង ចេញពីកំពង់ឆ្នាំងមក ពោធិសាត់ ចេញពីពោធិសាត់មកបាត់ដំបងដើរតាមថ្នល់ជាតិហ្នឹងរហូត ។

វណ្ណៈ : ចឹងអត់មានចូលព្រៃទេ?

សារិន : អត់ទេ ដើរតាមថ្នល់រហូតមកដល់បវេលនេះ មកដល់បវេលហ្នឹងរុះព្រៃហើយចេះតែរត់តាម គេទៅ ។

វណ្ណៈ : ចឹងពូរត់តាមផ្លូវជាតិហ្នឹងពូមានឃើញមានមនុស្សស្លាប់តាមផ្លូវទេ?

សារិន : កាលហ្នឹងដើរមិនសូវមានឃើញដែលហ្នឹង ខ្ញុំកាលហ្នឹងជិះឡានអីខ្វះ ។

វណ្ណៈ: បាទ ។

សារិន : ជួនកាលមានឡានចឹងសុំ គេជិះមកជួនណាគេចូលក្រសួងគេទៅយើងដើរទៀតមក ។

វណ្ណៈ : ចឹងរត់កាល៧៩ហ្នឹងយើងដើរប្រើរយៈពេលប៉ុន្មានខែបានមកដល់ព្រំដែន?

សារិន : កាលហ្នឹងដើរមួយឆ្នាំតែម្តងបានដល់ហ្នឹង ។

វណ្ណៈ : ចឹងមកដល់ហ្នឹងឆ្នាំ៨០?

សារិន : ឆ្នាំ៨០អីដូចជាឆ្នាំ៧៩ហ្នឹង ។

វណ្ណៈ : ៧៩ចឹងអត់បានមួយឆ្នាំទេ?

សារិន : អ! តែកាលហ្នឹងដូចជាយូរពេកដូចចង់មួយឆ្នាំហើយ ចុះដើររហូតហើយ ។

វណ្ណៈ : ប្រហែលជាខែប៉ុន្មានតាមស្មានទៅ?

សារិន : ចាំមិនបានទេ មិនសូវគិតនឹកនាទេរឿងហ្នឹង កាលហ្នឹងរត់មកហ្នឹងភ្លៀងកក់ម្តងៗខ្ពង់ជាខែបួន អីហ្នឹង "អ្នកជិតនិយាយថាកាលហ្នឹងទ័ពមិនសូវផាប់ទេ ប្រជាជនស្លាប់ច្រើន" ។

វណ្ណៈ : ចឹងខែ៤ហ្នឹងពូមកដល់ណា?

សារិន ៖ អាចខែ៨ហើយតាមមើល ។

វណ្ណៈ៖ អាចមកដល់ណា?

សារិន ៖ ខ្ញុំខែ៨ហ្នឹងមកដល់បវេលចេញពីបវេលហ្នឹងទៅប៉ៃលិន រុកតែព្រៃចាប់ផ្ដើមព្រៃហើយកាលហ្នឹងមកដល់ហ្នឹងមុនគេតែមិនមែនហ្នឹងនេះទេនៅខាងនោះភ្នំនោះ ។

វណ្ណៈ៖ បាទ ។

សារិន ៖ គេហៅថាភ្នំម៉ាឡៃនោះគេហៅផ្លូវ៥០២ មានផ្លូវគ្រួសក្រហមជំនាន់សម្ដេចសីហនុធ្វើផ្លូវហ្នឹងតាមមើលខ្លះគេហៅថាផ្លូវថៅកែយ៉ៃតែយើងមិនស្គាល់ថៅកែយ៉ៃយ៉ាងម៉េចទេ តែកាលហ្នឹងឮគេថាថៅកែយ៉ៃ ។

វណ្ណៈ ៖ ចឹងកាលឆ្នាំ៧៩មកដល់ក្នុងព្រៃហ្នឹងចលនាខ្មែរក្រហមជាមួយទាហានខាងរដ្ឋាភិបាលមានការវ៉ៃគ្នាហើយហើយ?

សារិន ៖ បាទ ។

វណ្ណៈ ៖ វ៉ៃហើយចឹងកាលហ្នឹងគេរៀបចំកំលាំងខ្មែរក្រហមយ៉ាងម៉េច?

សារិន ៖ កាលហ្នឹងគេរៀបចំទៅទប់ហ្នឹង ចេះតែទប់ទៅ ។

វណ្ណៈ៖ បាទ ។

សារិន ៖ គេប្រើយើងឲ្យទៅទប់ទៅ ។

វណ្ណៈ ៖ ចឹងកាលវ៉ៃហ្នឹងប្រពន្ធកូននៅក្រោយប្ដីទៅខាងមុខ?

សារិន ៖ បាទ!គេប្រើយើងទៅ ដូចថាប្រពន្ធនៅហ្នឹងទៅប្ដីទៅមុខទៅ ។

វណ្ណៈ ៖ ចឹងកាលហ្នឹងអត់មានប្រាក់ខែទេ?

សារិន ៖ អត់ផង បើកអង្ករឲ្យហូប ។

វណ្ណៈ ៖ ចឹងកាលហ្នឹងពីណាជាអ្នកដឹកនាំ?

សារិន ៖ កងពលកាលហ្នឹងលោកសុខភាព ។

វណ្ណៈ ៖ ចឹងកាលមុនសុខ ភាពពីណា?

សារិន ៖ អត់មាន ។

វណ្ណៈ ៖ ចុះតាហុង តាកនអីនោះ?

សារិន ៖ តាហុងមកក្រោយទេ តា កនគាត់កាន់នៅ៣២ខ្ញុំមិនបាននៅទេហ្នឹង ។

វណ្ណៈ ៖ ចុះនេះ?

សារិន ៖ ម៉ាឡៃតំបន់១០២ តា កន៣២ ។

វណ្ណៈ ៖ ចឹងខ្ញុំឮគេថា តា ហុងហ្នឹងធំជាងតា សុខ ភាពទៀត គេថាតា ហុងដឹកនាំតំបន់១០២និង តំបន់៣២ទៀតតើមែនទេ?

សារិន ៖ អាហ្នឹងមែនខាងលើហ្នឹងខ្ញុំមិនសូវដឹងដែរហ្នឹង ខ្ញុំនៅត្រង់ណាខ្ញុំដឹងតែមេហ្នឹងសុខ ភាព ។

វណ្ណៈ ៖ សុខ ភាពឥឡូវគាត់នៅធ្វើធំ?

សារិន ៖ ខ្ញុំមិនដឹងឥឡូវគាត់នៅណាមិនដែលឃើញមក ។

វណ្ណៈ ៖ ចឹងកាលមកដល់ម៉ាឡៃដំបូងពូឃើញមានព្រៃហ្នឹងយ៉ាងម៉េចដែរ បើនិយាយរឿងព្រៃ?

សារិន ៖ បើនិយាយរឿងព្រៃហ្នឹងចូលមិនចុះទេ និយាយពីដើមឈើវិញខ្ញុំមិននិយាយកុហក់ទេ ប៉ុនពាង នោះ ដើមឈើទាលដើមគគីរអីធំៗណាស់ ហើយសុទ្ធតែខ្លានិងដំរី តាមនេះសុទ្ធតែដានជើង ដំរីហើយនេះ បើព្រៃឫស្សីមានតែនៅជិតភ្នំបន្តិចទេ ក្រៅពីហ្នឹងសុទ្ធតែឈើហើយ ហើយ កាលហ្នឹងមានថៃលួចខ្លះផង ឃើញមានគល់ខ្លះធំៗខ្លះវាយកទៅខ្លះអត់ កាលនោះគេថាចៅកែ យ៉ិនៗតែយើងមិនដឹងដែលកាលនោះ ព្រោះយើងនោះតែយើងមកទីនេះអ្នកនៅទីនេះនិយាយ កាលហ្នឹង ។

វណ្ណៈ ៖ បាទ ។

សារិន ៖ កាលខ្ញុំរត់មកវេទនាដែលហ្នឹង ។

វណ្ណៈ ៖ ចឹងកន្លែងហ្នឹងមើលពន្លឺថ្ងៃមិនឃើញទេ?

សារិន ៖ អត់មានទេ ៧៩នេះខ្ញុំឈឺជ្រុះសក់ប្រពន្ធខ្ញុំក៏ជ្រុះដែរ នេះអ៊ំយ៉េងនេះដែលចូលមកសម្ភាសន៍ មិញនេះគាត់និយាយថាចាំមើលពីរនាក់ហ្នឹងអាណាងាប់មុន ថាឲ្យខ្ញុំចឹងតែម្តង ។

វណ្ណៈ ៖ បាទ ។

សារិន ៖ ខ្ញុំឈឺមុនប្រពន្ធប្រពន្ធខ្ញុំឈឺក្រោយទេ កាលហ្នឹងមិនមានពន្លឺថ្ងៃទេ ម៉ោង១២ថ្ងៃត្រង់ក៏រងាដែរ ខ្ញុំឆ្ងល់ដែលកាលហ្នឹង ។

វណ្ណៈ ៖ ចឹងអត់មានគ្រុបតង់អីឈើមានមិននាំគ្នាធ្វើផ្ទះ?

សារិន ៖ ឈើមានតែមិនមានអីប្រក់ បើមកមិនមានកៅស៊ូអីផងហ្នឹង ។

វណ្ណៈ ៖ ចឹងដូចជានៅក្រោមដើមឈើចឹង?

សារិន ៖ បាទ!នៅឈរអោបដៃចឹងដួនកាលទៅ ។

វណ្ណៈ ៖ ចឹងបើមានភ្លៀងមកចឹងយប់ឡើងដេកទាំងភ្លៀងទៅ?

សារិន ៖ ភ្លៀងមកនៅចឹងទៅដួនកាលមានកន្ទេលចឹងទៅ គ្រប់ពីលើបន្តិចទៅ ។

វណ្ណៈ៖ ចឹងមានកន្ទេលសុខចិត្តគ្របពីលើវិញ?

សារិន ៖ បាទ! អត្តុយ ។

វណ្ណៈ៖ ចឹងវេទនាណាស់?

សារិន ៖ បាទ ។

វណ្ណៈ ៖ ចឹងអ្នកមានកូនយ៉ាងម៉េចទៅ?

សារិន ៖ អ្នកមានកូនវេទនាណាស់ ខ្លះបានកៅស៊ូតូចមកទុកក្រុងកូនទៅ តែក្មេងកាលហ្នឹងមិនសូវមានរស់ដែរ កូនក្មេងកាលហ្នឹងរត់មកហ្នឹងយ៉ាប់ដែរវាចាញ់នោះ តូចៗចេះអីបើរស់ហ្នឹងសំណាងធំហើយ ។

វណ្ណៈ ៖ ចឹងបើចាស់ៗទប់មិនបានផង?

សារិន ៖ បាទ ។

វណ្ណៈ ៖ តែមានថ្នាំអីគេយកមកជួយព្យាបាលខ្លះដែរ?

សារិន ៖ មានជួយដែរ ជួនណាសេរ៉ូមួយច្នោកចាក់ឲ្យគ្នា១០នាក់នោះ បូមនិងសេរាំងចាក់តែម្ដងមិនព្យួរឲ្យយើងតែម្នាក់ឯងទេ ព្រោះវាអត់នោះកាលហ្នឹង ខ្ញុំចាក់អាសារាំងធំគេហ្នឹង១០សេៗចឹងទៅ ចាក់តែអាហ្នឹងចាក់មួយម្ជុលៗចឹងទៅ ។

វណ្ណៈ ៖ បាទ ។

សារិន ៖ ចាក់យូរៗទៅដឹងខ្លួនមកវិញទៅទៀត ខ្លះទៅទៀតទៅនៅដេកហ្នឹងខ្លះមិនដឹងខ្លួនទេ កាលឆ្នាំ៧៩ហ្នឹងព្រៃគ្មានមើលអីឃើញទេ ។

វណ្ណៈ៖ បាទ ។

សារិន ៖ តែពេលយប់ឡើងភ្លឺ ។

វណ្ណៈ ៖ យ៉ាងម៉េចបានភ្លឺ?

សារិន ៖ ភ្លឺជាតិស្អីគេនោះ ។

វណ្ណៈ ចឹងយប់ឡើងភ្លឺវិញ?

សារិន ៖ យប់ដើរជាប់ខោហើយនៅពេលយប់គ្មានទេ មនុស្សក្មេងទៅជាចាស់អស់ហើយ ចុះកាលហ្នឹងមានស្អីណាមើលពន្លឺថ្ងៃមិនឃើញផង ។

វណ្ណៈ ៖ ចឹងឮដូចថាមកជ្រុលខ្លួនជាប់ផុងចឹងមានស្រណោះផ្ទះទេ នៅពេលឈឺចឹង?

សារិន ៖ ស្រណោះណាស់តែមិនដឹងជាទៅច្រកណា ហ៊ានតែដើរចេញមិនស្រួលវង្វេង បើចេញទៅមានវាលស្រែមិនអីទេ រកផ្លូវមិនឃើញទេ ហ៊ានតែដើរចំងាយ១០០ម៉ែត្ររកផ្លូវមកវិញមិនឃើញឥឡូវហើយ ។

វណ្ណៈ ៖ ចឹងមានន័យថា បើចូលមកដល់ហ្នឹងហើយមិនដឹងជាខាងណាលិចខាងណាកើតចង់ទៅស្រុកវិញមិនឃើញទេ?

សារិន ៖ អត់ទេ បើយើងចង់ទៅទាល់តែមានមេខ្យល់នាំទៅបានទៅបាន មានអ្នកធ្លាប់ស្គាល់ភូមិសាស្ត្រ បានដើរទៅបាន ។

វណ្ណៈ ៖ បាទ ។

សារិន ៖ ដើរបានត្រឹមភ្នំយើងដើរទៅព្រឹកល្ងាចហ្នឹងបាន តែទៅហួសពីហ្នឹងរកផ្លូវមកវិញមិនឃើញឥឡូវហើយ ។

វណ្ណៈ ៖ បាទ ។

សារិន ៖ ហើយស្គាល់តាមមាត់អូរដីថៃនេះ តាមមែនទែនទៅមាត់អូរនេះសុទ្ធទែប្រឡាផ្តៅធំៗហ្នឹង ។

វណ្ណៈ ៖ ចឹងកាលហ្នឹងកាលដែលយើងនៅជាមួយយួនហ្នឹងអត់មានសម្ភារមកជួយផ្គត់ផ្គង់ច្រើនដែរ?

សារិន ៖ អត់ មានខ្លះដែលដូចជាអង្ករអើយកមកចែកឲ្យហូបទៅ ។

វណ្ណៈ ៖ ចឹងកាលហ្នឹងទាហានខ្មែរក្រហមអីតាមពូគិតមើល កាលហ្នឹងតំបន់ហ្នឹងមានតែទាហានខ្មែរក្រហមអត់មានទាហានប៉ុភអីទេ?

សារិន ៖ កាលហ្នឹងប៉ុភក៏មានលាយខ្លះដែលកាលហ្នឹង ។

វណ្ណៈ៖ ក្រោយមកទៀតបានមាន?

សារិន ៖ ប៉ុភកាលមុនមាននៅលើៗគេហៅស្ទឹងសម្ពោញនៅខាងភ្នំឆត្រអីហ្នឹង ។

វណ្ណៈ ៖ ចឹងនៅខាងហ្នឹងជាតំបន់ខ្មែរក្រហមសុទ្ធ?

សារិន ៖ ជាកន្លែងខ្មែរក្រហមកាលហ្នឹង ។

វណ្ណៈ ៖ ចឹងកាលហ្នឹងមានគ្នាច្រើនទេ កាលគស៊ូនៅជាមួយទាហានយួនកាលហ្នឹង?

សារិន ៖ មានច្រើនដែរ ។

វណ្ណៈ៖ ច្រើនដែរ?

សារិន ៖ បាទ ។

វណ្ណៈ ៖ ចឹងមានស្លាប់ដោយសាចាញ់ច្រើនទេ?

សារិន ៖ មានស្លាប់ដោយសារចាញ់និងមីន ។

វណ្ណៈ ៖ ហើយខាងនោះស្លាប់ច្រើនទេ?

សារិន ៖ ស្លាប់ដោយសារមីនដូចគ្នាដូចគ្នា ។

វណ្ណៈ ៖ ចឹងទាហានយួនស្លាប់ច្រើនដែរ?

សារិន ៖ ទាហានយួនមកទីនេះស្លាប់ច្រើនដោយសារចាញ់ហ្នឹងចុះមកនៅតាមភ្នំអីនេះ ។

វណ្ណៈ ៖ ចឹងមានយួនមកដល់ហ្នឹងដែរ?

សារិន ៖ នេះយួនមកនៅហ្នឹងភ្នំនេះ ។

វណ្ណៈ ភ្នំនេះហ្នឹង?

សារិន ៖ បាទ ។

វណ្ណៈ ៖ ចឹងហ្នឹងគេហៅភ្នំអី?

សារិន ៖ ហ្នឹងគេហៅថាភ្នំរូង"អ្នកជិតនិយាយថា បើយួនមកនៅហ្នឹងខ្មែរក្រហមទៅនៅណា?"សារិន ប្រាប់ថាខ្មែរក្រហមនៅដីថៃ ។

វណ្ណៈ ៖ បាទ!នៅក្បែរៗហ្នឹងទៅ?

សារិន ៖ បាទ ។

វណ្ណៈ ហើយវៃបុកទៅនោះទៅ?

សារិន ៖ បាទ! ដល់ពេលនេះដកទៅវិញអស់ទៅយើងចូលមកនៅវិញមក ។

វណ្ណៈ បាទ!ឆ្នាំ៨០ជាង?

សារិន ៖បាទ!បានដកមកបានកើតភូមិជាថ្មីម្ដងទៀតហ្នឹងបានរីកចំរើនមកដល់សព្វថ្ងៃហ្នឹង មានថ្នល់ មាន ផ្ទះអីធំដុំហ្នឹង ។

វណ្ណៈ ៖ កាលហ្នឹងដូចថាព្រៃឈើអីហ្នឹងខាងណាជាអ្នកកាប់បានជាពាយហ្នឹង?

សារិន ៖ ព្រៃឈើហ្នឹងមែនទែនបងប្អូនកាប់អារលក់ខ្លះចឹងទៅណាស់ ។

វណ្ណៈ បាទ ។

សារិនៈ អារលក់ឲ្យថៃចឹងទៅ ព្រោះកាលនោះដាច់អន្តរអីហើយ ។

វណ្ណៈ បាទ ។

សារិន ៖ ដូរអន្តរចឹងទៅអារណាដៃយើងហ្នឹង ខ្លះអារលក់ទៅខ្លះអារទុកធ្វើផ្ទះចឹងទៅ អារហើយលីខ្លួន ឯងមួយសន្ទឹកៗមក ដល់ក្រោយមមកទៀតមានម៉ាស៊ីនកាត់ឈើព្រងៅងៗហ្នឹងមក បានពាយ ក្លាយជាចំការតែម្ដង ។

វណ្ណៈ ៖ ឆ្នាំណាដែលអស់ព្រៃ?

សារិន ៖ មែនទែនទៅឆ្នាំដែលផ្ដាច់ខ្លួនហើយ ។

វណ្ណៈ ចឹងផ្ដាច់ខ្លួនហើយនៅឆ្នាំ៩៦?

សារិន ៖បាទ!ផ្ដាច់ខ្លួនហើយអាហ្នឹងចាប់ផ្ដើម មានមនុស្សចូលមកពីក្នុងកាន់តែច្រើនណាស់បងប្អូនចេះ តែមកទៅមានចាប់ដីអីចឹងទៅ ចាប់ផ្ដើមធ្វើចំការហើយ ។

វណ្ណៈ ៖ ចឹងចាប់ផ្ដើមប្រែក្លាយចាចំការហើយ?

សារិន ៖ បាទ! កើតចំការកើតស្រែចឹងទៅបងប្អូនមកទៅបានមួយប្លង់ៗចឹងទៅគ្រប់គ្នាទៅបានធ្វើចំការ គ្រប់គ្នាទៅក៏ធ្វើចំការគ្រប់គ្នាទៅ ។

វណ្ណៈ ៖ ចឹងដល់ពេលកាលហ្នឹងដូចថាកាលហ្នឹងវៀតណាមដកទៅចិនលែងជួយហើយកាលហ្នឹងបងខ្មែរក្រហមដោះស្រាយខ្លួនឯង?

សារិន ៖ ខ្មែរក្រហមដោះស្រាយខ្លួនឯងតែម្ដង ។

វណ្ណៈ ៖ ចឹងកាលហ្នឹងធ្វើស្រូវបានដោះដូរជាមួយថៃមិនអាចដោះដូរទៅខាងក្នុងបានទេ?

សារិន ៖ អត់ទេ ដោះដូរបានជាមួយតែថៃដូចជាពោតសណ្ដែកអីហ្នឹង ។

វណ្ណៈ ៖ ថៃចូលមកទិញដល់ហ្នឹងឬអត់ទេ?

សារិន ៖ ថៃកាលលើកមុនចូលមកទិញដល់ហ្នឹង តែឥឡូវភាគច្រើនខ្មែរយើងទិញច្រើន ។

វណ្ណៈ៖ ចឹងមានឈ្មួញកណ្ដាលអី?

សារិន ៖ បាទ ។

វណ្ណៈ ៖ ចឹងនៅហ្នឹងដាំដំណាំតែសំខាន់ជាងគេមានស្អីខ្លះ?

សារិន ៖ មានពោត សណ្ដែកនិងដំឡូង ។

វណ្ណៈ ៖ ចឹងស្រូវ?

សារិន ៖ ស្រូវមានដីស្រែភាគតិច បានគ្រាន់តែហូបនៅទីនេះទិញអង្ករហូបខ្លះ ។

វណ្ណៈ ៖ ចឹងបងប្អូននៅស្រុកម៉ាឡៃច្រើនតែទៅស៊ីឈ្នួលនៅម៉ាឡៃឬមួយមិនសូវទេ?

សារិន ៖ មានទៅដូនកាលខ្វែរចរាល់ខ្លួនគាត់ចឹងទៅណាស់ ដូចថាគាត់ប្រមូលផលអស់ហើយគាត់ទៅស៊ីឈ្នួលនៅថៃ តែវិលវិញល្ងាចទេ តែឥឡូវមិនសូវមានអ្នកទៅទៀតទេ ព្រោះមានដីចំការធ្វើមិនសូវមានពេលទំនេរទេ បើពីមុនទាំងខ្ញុំអីហ្នឹងទៅកាច់ពោតឲ្យថៃ កាប់អំពៅអីហ្នឹង ដល់ខ្ញុំមានដីស្រែចំការធ្វើបានចឹងទៅខ្ញុំឈប់ទៅ ។

វណ្ណៈ ៖ ចឹងឆ្នាំណាដែលបងប្អូននៅស្រុកម៉ាឡៃហ្នឹងទៅស៊ីឈ្នួលនៅថៃ?

សារិន ៖ កាលហ្នឹងចាប់ពីឆ្នាំ១៩៩៦ដល់ឆ្នាំ២០០៤កាលហ្នឹងទៅស៊ីឈ្នួលឲ្យថៃសឹងតែទាំងអស់គ្នាទើបតែឆ្នាំ២០០៥ដល់បច្ចុប្បន្នមិនសូវមានអ្នកទៅស៊ីឈ្នួលនៅថៃទេ ។

វណ្ណៈ ៖ ចឹងអ្នកម៉ាឡៃមិនសូវទៅស៊ីឈ្នួលតែមានមកពីខាងក្នុងវិញ?

សារិន ៖ បាទ!អ្នកម៉ាឡៃមិនសូវមានទេ មានអ្នកចំណាកស្រុកវិញ អ្នកចំណាកស្រុកដូនកាលមកស្នាក់នៅភូមិខ្ញុំចឹងទៅមកសុំស្នាក់នៅរកស៊ីនៅពេលបានលុយទៅស្រុកវិញចឹងទៅ ចាំមើលរួចរាល់ស្រែមកពេញហ្នឹងទៀតហើយ ។

វណ្ណៈ៖ ចឹងឥឡូវច្រើនតែមកពីក្នុង?

សារិន ៖ បាទ!ឥឡូវភាគច្រើន ច្រើនតែចំណាក់ស្រុកមកពីក្នុងហ្នឹង មកដូនកាលមកស្នាក់នៅភូមិខ្ញុំចឹងទៅ មកសុំច្បាប់សុំស្នាក់នៅរកស៊ីបានលុយបានកាក់ក៏ត្រឡប់ទៅស្រុកវិញចឹងទៅ ។

វណ្ណៈ  បាទ ។

សារិន ៖ មកស្នាក់នៅច្រើនតែតើកន្លែងនៅមិនហ្នឹងណាស់ ។

វណ្ណៈ  បាទ ។

សារិនៈ  កន្លែងផ្ទះតាអោមិនហ្នឹង ចាំមើលរួចរាល់ស្រែហ្នឹងមកពេញហ្នឹងទៀតហើយ ។

វណ្ណៈ ៖ ចឹងខ្ញុំចង់ដឹងថាប្រជាជនដែលរស់នៅក្នុងភូមិរបស់អ៊ឹមានប៉ុន្មានគ្រួសារដែរ?

សារិន ៖ កាលមុនខ្ញុំគ្រប់គ្រងដំបូងមកមានតែ៧០គ្រួសារទេ ។

វណ្ណៈ ៖ ចឹងឥឡូវ?

សារិន ៖ ឥឡូវឡើងដល់១៥៨គ្រួសារហើយថ្ងៃមុនទៀតឡើង១៨០សង្ស័យបន្តិចទៀតឡើងដល់ ២០០ទៅ៣០០ដឹង ។

វណ្ណៈ ៖ ចឹងប្រជាជនមានប៉ុន្មាននាក់ក្នុងភូមិពូ?

សារិន ៖ ប្រជាជនមានជាង៨០០នាក់ ។

វណ្ណៈ  មាន៨០០០ឬ៨០០?

សារិនៈ  អត់ទេ ជាង៨០០ទេ ពិបាកទៀតបញ្ជីរនៅផ្ទះនោះ ។

វណ្ណៈ ៖ ចឹងមិនអីទេ ចឹងមានជាង៨០០នាក់?

សារិន ៖ បាទ ។

វណ្ណៈ  ជាង៨០០នាក់មាន១៨០គ្រួសារ?

សារិន ៖ បាទ ។

វណ្ណៈ ៖ ចឹងប្រជាជនទាំងអស់ជាង៨០០នាក់ហ្នឹងភាគច្រើនប្រកបមុខរបរធ្វើអី?

សារិន ៖ នៅស្រុកនេះភាគច្រើនធ្វើតែចំការហ្នឹងនិងមានលក់ដូរបន្តិចបន្តួចចឹងទៅ ។

វណ្ណៈ ៖ ចឹងពូសង្កេតឃើញយ៉ាងម៉េចដែលប្រជាជនយើងដែលរស់នៅក្នុងភូមិរបស់ពូហ្នឹងថាតើជីវភាព របស់គាត់ពីមុនយ៉ាងម៉េចហើយមកដល់បច្ចុប្បន្ននេះជួបបញ្ហាអីខ្លះកើតឡើងក្នុងភូមិពូ?

សារិន ៖ ក្នុងនេះមែនទែនកន្លងមកជីវភាពគាត់ពីមុនមកមានការលំបាកមែន សូម្បីផ្ទះសំបែងមើលមិន យល់ទេ កាលពីមុនមកនោះ ។

វណ្ណៈ  បាទ ។

សារិន ៖ សាលារៀនហ្នឹងមានសាលារៀនឈើដំបូងនោះ សាលាឈើហ្នឹងសហការគ្នាធ្វើជួយគ្នាធ្វើទេ ក្រោយមកទៀតបានប្រជាពលរដ្ឋមានការរីកចំរើនគ្រួសារហ្នឹងកាន់តែច្រើនឡើងទៅក៏មើល ទៅទេសភាពក៏មានការរីកចំរើនមានផ្ទះសំបែងត្រឹម ត្រូវមានមន្ទីរពេទ្យត្រឹមត្រូវលែងឈឺ ស្កាត់អីទាំងអស់ហ្នឹង ឃើញថាមានភាពរីកចំរើនពីមួយឆ្នាំទៅមួយឆ្នាំ ។

វណ្ណៈ ៖ ចឹងនៅពេលមានសាលារៀនមានមន្ទីរពេទ្យឲ្យកូនក្មេងរៀនបានហ្នឹង ពូសង្កេតឃើញមានចាប់តាំងពីឆ្នាំណាដែលមានសាលារៀនហ្នឹង?

សារិន ៖ សាលារៀនដំបូងបង្អស់កាលដែលធ្វើសាលាឈើ ។

វណ្ណៈ៖ ធ្វើសាលាឈើនៅឆ្នាំណា?

សារិន ៖ សាលាឈើមានតាំងពីយើងចរចារគ្នានៅប៉ារីសចឹង ។

វណ្ណៈ៖ កាលជំនាន់អ៊ុនតាក់កាលមិនផ្តាច់ខ្លួន?

សារិន ៖ កាលអ៊ុនតាក់សាលាឈើ ។

វណ្ណៈ ៖ ចឹងនៅពេលមានសាលាថ្មមានមន្ទីរពេទ្យអីមានតាំងពីឆ្នាំណា?

សារិន ៖ ក្រោយពេលផ្តាច់ខ្លួនហើយ មានមន្ទីរស្នាក់នៅសម្រាកស្រួលបួល មានបែកភូមិឃុំ កាលពីមុនមិនមានភូមិសង្កែអីទេណាស់ ។

វណ្ណៈ៖ បាទ ។

សារិនៈ គ្រាន់តែហៅថាសង្កែៗចឹងទៅ ។

វណ្ណៈ៖ បាទ ។

សារិនៈ ដល់ភ្នំរូងហៅភ្នំរូងចឹងទៅ ។

វណ្ណៈ៖ បាទ ។

សារិនៈ បឹងបេងហៅបឹងបេងចឹងទៅ ដល់ក្រោយផ្តាច់ខ្លួនហើយសម្តេចនាយកបានបង្កើតឲ្យមានឃុំបឹងបេងហ្នឹងមាន៥ភូមិណាស់ ។

វណ្ណៈ ៖ បាទ ។

សារិន ៖ ភូមិសង្កែ ភូមិភ្នំរូង ភូមិចំបក់ ភូមិជ្រៃនិងភូមិល្វា មានមួយភូមិចឹងមកកាលមុន ។

វណ្ណៈ៖ ចឹងឃុំបឹងបេងមាន៥ភូមិ?

សារិនៈ បាទ ។

វណ្ណៈ៖ ចឹងភូមិហ្នឹងគេហៅភូមិសង្កែ?

សារិនៈ បាទ ។

វណ្ណៈ៖ គេហៅភូមិអីទៀត?

សារិនៈ ភូមិភ្នំរូង ។

វណ្ណៈ៖ មានអីទៀត?

សារិនៈ ភូមិចំបក់ ភូមិជ្រៃ ភូមិល្វា ។

វណ្ណៈ ៖ ខ្ញុំចង់សួរភូមិមួយៗក្រែងលោពូស្គាល់ប្រវត្តិហេតុអីបានជាហៅថាភូមិសង្កែមានអីចំណាំ?

សារិន ៖ កាលហ្នឹងភូមិហ្នឹងមានដើមសង្កែទាំងអស់ ដើមសង្កែធំៗ ចឹងបានជាគេហៅសង្កែរហូតតែម្ដងទៅ ។

វណ្ណៈ ៖ ចឹងភូមិភ្នំរូង មានភ្នំរូង?

សារិន ៖ មានភ្នំរូងនោះ ។

វណ្ណៈ ៖ ចឹងភូមិចំបក់?

សារិន ៖ ទេ ភូមិហ្នឹងមិនដឹងជាយ៉ាងម៉េចដែរ មិនជាយ៉ាងម៉េចទេហៅភូមិចំបក់ហ្នឹង ។

វណ្ណៈ ៖ ចឹងភូមិជ្រៃ?

សារិន ៖ ភូមិជ្រៃហ្នឹងក៏មិនបានដឹងយ៉ាងម៉េចដែរ ។

វណ្ណៈ ៖ ចឹងភូមិល្មា?

សារិន ៖ ភូមិល្មាក៏លំបាកដែរ "អ្នកអន្ទុយជិតនិយាយថាមានអូរល្មា" ។

វណ្ណៈ ៖ ចឹងបឹងបេង?

សារិន ៖ បឹងបេងមែនទែន កាលហ្នឹងមានសុទ្ធតែដើមបេងច្រើនមែនទែន សុទ្ធតែជំពូកបេងចឹងបានជាគេដាក់ថាភូមិបឹងបេងហ្នឹងត្រូវតែម្ដង ។

វណ្ណៈ៖ ព្រោះមានដើមបេងច្រើន?

សារិនៈ បាទ!តាមខ្ញុំមើល ។

វណ្ណៈ ៖ ចឹងពូក្រោយឆ្នាំ៧៩មកក្រោយមកនៅពេលជិតផ្ដាច់ខ្លួនហ្នឹង?

សារិនៈ បាទ ។

វណ្ណៈ៖ ពូថាមានប្រមូលទ្រព្យសម្បត្តិប្រជាជនដាក់រួមដូចជិនាន់បីឆ្នាំឬមានការកើតឡើងចឹងមែនឬមិនមែនទេ?

សារិន ៖ អត់ទេ ឃើញប្រមូលក្រោយមកប្រមូលតែម៉ាស៊ីន ។

វណ្ណៈ ៖ នៅឆ្នាំណាប្រមូល?

សារិន ៖ ប្រមូលម៉ាស៊ីនដូចជាឆ្នាំណាទេ ដូចជាចរចារគ្នានៅប៉ារីសត្រីភាគីម៉េចនោះណាស់យ៉ាងម៉េចទេកាលហ្នឹងមានប្រមូលម៉ាស៊ីនឃើញតែម្ដងហ្នឹង ។"អ្នកជិតខាងនិយាយថាពួកហ្នឹងឯងសមាហរណ៍កម្ម៩៦ហ្នឹង ដោយសាររឿងប្រមូលរទេះគោហ្នឹងកាលហ្នឹងមិន ទាន់ដើរប្រមូលផងទេ ម៉ាស៊ីននៅផ្ទះ ទើបតែមានការឃោសនា ។

វណ្ណៈ ៖ តែតាមខ្ញុំដឹងមានកន្លែងខ្លះបានប្រមូលខ្លះហើយ?

សារិន ៖ បែបមានប្រមូលនៅកន្លែង៣២ដីង តែនៅទីនេះមិនដែលឃើញប្រមូលខ្ញុំនៅហ្នឹងមិនដែលឃើញ យើងហ្នឹងមិនទាន់ឃើញប្រមូលរឿងរទេះរឿងគោ ។

វណ្ណៈ ៖ ចឹងមានអ្នកខ្លះថា ផ្ដើមគំនិតចេញពីតា សុន សេនតើរឿងហ្នឹងជារឿងពិតឬមួយមិនមែនទេ កាលហ្នឹង?

សារិន ៖ រឿងហ្នឹងខ្ញុំឮតែគេនិយាយដែរ គេថា សុន សេនហ្នឹង ។

វណ្ណៈ៖ បាទ ។

សារិនៈ អ្នកជិតខាងជាមនុស្សស្រីនិយាយថា"គេថាតស៊ូដើម្បីឯករាជ្យ តែខំតស៊ូនៅតែដូចមុនដែលមិនបាច់បំរើអីទេ"សារិននិយាយវិញ កាលផ្ដាច់ខ្លួនហ្នឹងបានរឿងគ្នាហ្នឹង ។

វណ្ណៈ៖ បាទ ។

សារិនៈ "អ្នកជិតនិយាយថាមិនចូលសមាហរណ៍កម្មទេ" សារិននិយាយវិញថា ត្រូវតែចូលគេចមិនរួចទេ ព្រោះទៅលែងរួចហើយទៅមិនរួចព្រោះវាដល់ដំណាក់កាលហើយ អាហ្នឹងបើតាមយើងសង្កេតមើល ព្រោះមនុស្សលែងចង់ទៅធ្វើជួយហើយហ្នឹង មានទៅអីម្នាក់ឯងរួចនោះ កាលហ្នឹងទាំងគេទាំងយើងគិតរឿងរៀងខ្លួនមានពីណាទៅជួយទេ កាលហ្នឹងមានឮថាដែលតែមិនទាន់មានប្រមូលអីផង តែសុន សេនហ្នឹងមានគំនិតប្រមូលមែនហ្នឹង ។

វណ្ណៈ ៖ ចឹងពូនៅហ្នឹងមានដឹងពីការស្លាប់របស់សុន សេនទេ?

សារិន ៖ អត់បានដឹងទេ មិនដឹងជាស្លាប់នៅណាឃើញតែរូបថតគេថតមក ។

វណ្ណៈ ៖ ចឹងកាលសម្ដេចសីហនុចុះមកតំបន់សាគាំងហ្នឹងពូមានបានដឹងទេ?

សារិន ៖ កាលហ្នឹងដឹងថាចុះមកកន្លែងសាគាំងហ្នឹង ខ្ញុំមិនដែលបានទៅទេ ដូចខ្ញុំមិនឆាយបានទៅទេ មិនបានទៅទទួលទៅអីគេទេកាលហ្នឹងមានលោកតា អៀង សារីគាត់ទទួលចឹងទៅណាស់ ។

វណ្ណៈ៖ បាទ ។

សារិនៈ យើងតូចតាចចឹងមិនសូវបានទៅទេ ។

វណ្ណៈ ៖ ចឹងពូគិតថា កាលមិនទាន់ផ្ដាច់ខ្លួននិងផ្ដាច់ខ្លួនហើយពូគិតថាមួយណាស្រួលជាង កាលនៅជាមួយខ្មែរក្រហមដល់ពេលផ្ដាច់ខ្លួនហើយតើមួយណាស្រួលជាង យើងគិតទស្សនៈផ្ទាល់ខ្លួន?

សារិន ៖ ខ្លួនខ្ញុំផ្ទាល់តែម្ដងខ្ញុំវិភាគទៅនៅពេលដែលផ្ដាច់ខ្លួនហើយស្រួលជាង ។

វណ្ណៈ៖ បាទ ។

សារិនៈ ខ្ញុំគិតថាស្រួលមានសិទ្ធធ្វើស្រែចំការខ្លួនឯង ។

វណ្ណៈ៖ អ្នកណាខំអ្នកហ្នឹងបាន?

សារិនៈ អ្នកណាខំអ្នកហ្នឹងបានតែម្ដងអត់មានពិបាកបើយើងមិនខំគឺអត់ហើយ ។

វណ្ណៈ៖ បាទ ។

សារិនៈ  គឺចឹងតែម្តងមានសិទ្ធការកូនចៅពេញទីនិយាយរួមមានសិទ្ធតែម្តង  កុំឲ្យតែទៅលួចទៅប្លន់គេថាផ្ទើខ្លួនឯង  មានសាលារៀនមានវត្តអារាមបូជាគ្រប់បែបយ៉ាងទាំងអស់មិនលំបាក  កាលពីកាលពីមុនរកតែវត្តរកតែព្រះមួយអង្គគ្មាន ។

វណ្ណៈៈ  ចឹងឥឡូវពីណាខំរកអ្នកហ្នឹងបាន?

សារិនៈ  បាទ!អ្នកណាខំបាន ។

វណ្ណៈៈ  ចឹងពីណាមិនខំ?

សារិនៈ  ពីណាមិនខំអាហ្នឹងតាមដំណើរ ។

វណ្ណៈ ៈ  តែមានអ្នកខ្លះនិយាយចឹងដែលថាកាលពីមុនមិនមានភ័យព្រួយរឿងអត់ស៊ីទេដឹងតែគេចែកឲ្យហូត?

សារិនៈ បាទ ។

វណ្ណៈៈ តែយើងក៏គ្មានសិទ្ធសេរីភាព?

សារិនៈ អត់មានសិទ្ធទេ កាលនោះបើឥឡូវនេះពេញហើយ ។

វណ្ណៈៈ  បាទ!ចឹងម្យ៉ាងម្នាក់?

សារិន ៈ ខ្ញុំថាអត់មានម្យ៉ាងទេ ខ្ញុំថាឥឡូវនេះស្រួលតែម្តង ខុសគ្នាឆ្ងាយតែម្តង ។

វណ្ណៈ ៈ  ចឹងក្រោយផ្លាច់ខ្លួនទេ បានជាមានឈ្មោះស្រុកម៉ាឡៃពីមុនហៅយ៉ាងម៉េចដែរ?

សារិន ៈ  កាលពីមុនហៅតែម៉ាឡៃៗ ។

វណ្ណៈៈ  ម៉ាឡៃគ្មានស្រុកទេ?

សារិនៈ  កាលមុនគេហៅភ្នំម៉ាឡៃតែភ្នំម៉ាហ្នឹងអ្នកទាំងអស់ហ្នឹងមិនដឹងថានៅត្រង់ណាផង  កាលហ្នឹងគេថាម៉ាឡៃៗភ្នំយាយសំចឹងទៅ ។

វណ្ណៈៈ  បាទ ។

សារិនៈ  កាលខ្ញុំមកដល់ដំបូងគេថាភ្នំយាយសំ នេះភ្នំម៉ាឡៃចឹងទៅ ។

វណ្ណៈ ៈ  ចឹងភ្នំម៉ាឡៃនៅខាងណាវិញ?

សារិន ៈ  នៅខាងនេះ  នោះអាភ្នំនោះ  ភ្នំម៉ាឡៃភ្នំវ៉ាងយើងហ្នឹង  ភ្នំវ៉ាងហ្នឹងគេហៅភ្នំម៉ាឡៃ  កាលហ្នឹងគ្រាន់ខ្ញុំមកដល់គេថាភ្នំម៉ាឡៃ  តែយើងដឹងតាមគេដែលទេណា  តែគ្រាន់គោលដៅម៉ាឡៃមិនដឹងជាយ៉ាងម៉េចខ្ញុំមិនដឹងដែរ ។

វណ្ណៈ ៈ  បាទ ។

សារិន ៈព្រោះយើងមិនបានកើតជានៅទីនេះ ។

វណ្ណៈ ៈ  ចឹងកាលឆ្នាំ៧៩ដល់៩៦មានវត្តហើយឬនៅ?

សារិន ៖ ៧៩ដល់៩៦អត់មានវត្តទេ ។

វណ្ណៈ ៖ ចឹងវត្តទើបតែកើតឥឡូវហ្នឹងទេ?

សារិន ៖ បាទ! កើតនៅពេលដែលចូលសមាហរណកម្មហើយ ចាប់ផ្តើមកសាងវត្តអារាមពេញតែម្តង កសាងភូមិពិតប្រាកដហ្នឹង ។

វណ្ណៈ ៖ ចឹងកាលឆ្នាំ៧៩-៨០-៨១-៨២ហេតុអីនៅខាងតំបន់ហ្នឹងមិនមានបង្កើតវត្តអីកំពង់តែ សង្គ្រាមឬមួយយ៉ាងម៉េច?

សារិន ៖ ប្រហែលជាចឹងតាមខ្ញុំវិភាគមើលទៅ ព្រោះមិនមានឃើញវត្តអីហើយម្យ៉ាងប្រជាពលរដ្ឋដូចជាពិបាករឿងធ្វើបុណ្យធ្វើអីដូចជាគ្មានលោកសង្ឃអីផង ។

វណ្ណៈ ៖ ចឹងមានមីងៗខ្លះនិយាយថាពីឆ្នាំ១៩៧៩ដល់៨៥ នៅពេលរៀបការចាប់ដៃគ្នាដូចជំនាន់ខ្មែរក្រហមដែរ?

សារិន ៖ អត់ទេ មានសែន ។

វណ្ណៈ ៖ តែគាត់និយាយប្រាប់ថាឆ្នាំ៨១-៨២ចាប់គូរម្តង៥គូរទៅ៦គូរដែរ តែមានអាចារ្យសែនតែគ្មានលោកសង្ឃទេ?

សារិន ៖ បាទ! គ្មានលោកសង្ឃទេ ខ្លះទៅសែនតាមជំរំចឹងទៅ ខ្ញុំនៅជំរំស្រះកែវ ។

វណ្ណៈ ៖ ចឹងពូការនៅជំរំ?

សារិន ៖ ខ្ញុំការតាំងពីនៅភ្នំពេញ ការឲ្យនៅភ្នំពេញចឹងទៅការបានប៉ុន្មានទេខ្ញុំរត់តែម្តង អ្នកដែលការស្រករខ្ញុំគេបែកគ្នាអស់ហើយ ។

វណ្ណៈ ៖ ចឹងនៅក្នុងភូមិសព្វថ្ងៃមានសាលារៀនប៉ុន្មាន?

សារិន ៖ ភូមិហ្នឹងមានសាលារៀនមិនហ្នឹងតែពីរហ្នឹង ។

វណ្ណៈ ៖ ចឹងនៅក្នុងឃុំបឹងបេងហ្នឹងមានសាលារៀនប៉ុន្មាន?

សារិន ៖ នៅឃុំបឹងបេងហ្នឹងមានអនុវិទ្យាល័យតែមួយទេនៅបឹងបេងនៅឃុំបឹងបេងហ្នឹង ។

វណ្ណៈ៖ តែចង់និយាយថាអនុវិទ្យាល័យនៅបឹងបេងហ្នឹងមានតែមួយទេ?

សារិនៈ មានមួយហ្នឹង មានតែមួយហ្នឹងទេ ។

វណ្ណៈ៖ ចឹងមានសាលាបឋមសិក្សាប៉ុន្មាន?

សារិនៈ សាលាបឋមនេះខាងនេះពីរអគារខាងនោះពីរអគារ របស់សម្តេចឥឡូវអត់មានបង្រៀនផង ។

វណ្ណៈ ៖ ចឹងមានប៉ុន្មានកន្លែង?

សារិន ៖ មានតែពីរកន្លែងហ្នឹង មានបឹងបេងនិងភូមិសង្កែ ។

វណ្ណៈ៖ គេដាក់សាលាអនុវិទ្យាល័យបឹងបេង?

សារិនៈ  ប៊ីងបេងបាទ! ។

វណ្ណៈ  អនវិទ្យាល័យសង្កែ?

សារិនៈ  អត់ទេ  សាលាបឋមសង្កែ ។"អ្នកនៅជិតនិយាយថាមានសម្តេចហ៊ុន  សែនសង្កែមានហ៊ុន សែនប៊ីងបេង ឃើញផ្លាកគេដាក់ហ្នឹង" ។

វណ្ណៈ  ចឹងសាលាហ្នឹងសម្តេចហ៊ុន សែនជួយ?

សារិនៈ  បាទ! ជួយសាលាពីរមួយឃុំហ្នឹង ។

វណ្ណៈ  មានមន្ទីរពេទ្យហើយឬនៅ?

សារិនៈ  មន្ទីរពេទ្យក្នុងភូមិមិនទាន់មានទេ ។

វណ្ណៈ :  ចឹងឃុំហ្នឹងមានវត្តហើយឬនៅ?

សារិន :  មានវត្តចំនួនពីរ  មានវត្តភ្នំរូងមួយ ។

វណ្ណៈ :  ចឹងក្រោយសមាហរណ៍កម្មបានមានវត្តហ្នឹង?

សារិន :  បាទ ។

វណ្ណៈ :  ចឹងនៅពេលដែលកំពង់តែវៃគ្នាជាមួយវៀតណាមមានប្រជាជនរស់នៅខាងក្នុងរត់ទៅជាយ ដែនដើម្បីឆ្លងទៅប្រទេសទីបី ដូចជាទៅអាមេរិចមានទេ?

សារិន :  អត់មានទេ ។

វណ្ណៈ :  ចឹងអត់មានដែលជួបអ្នកពីខាងក្នុងរត់មកទេ?

សារិន :  បាទ!មានអ្នកចង់មករស់នៅកន្លែងហ្នឹងមាន ខ្លះរត់ចេញពីហ្នឹងមកធ្វើផ្ទះនៅហ្នឹងទៅ ។

វណ្ណៈ :  តែខ្ញុំបានជួបបងប្អូនខ្មែរក្រហមនៅខាងភ្នំព្រឹកថា  មានប្រជាជនរត់មកកាលឆ្នាំ១៩៨១-៨២ មានខាងខ្មែរក្រហមជាអ្នកនាំផ្លូវតែយកកំរៃដើងសារខ្លះដែរ?

សារិន :  កាលហ្នឹងខ្ញុំបានឮដែរ  មានខាងកងទ័ពជូនទៅជួបថៃអីចឹងទៅណាស់ ។

វណ្ណៈ  បាទ ។

សារិនៈ  តែដឹងថាកំរៃមិនកំរៃមិនដឹងទេ  តែជូនកាលចង់ទៅប្រទេសណាប្រទេសណីខ្ញុំឮដែលហ្នឹងតែមិន បានឃើញផ្ទាល់ ។

វណ្ណៈ  បាទ ។

សារិនៈ  គ្រាន់តែឮៗ ។

វណ្ណៈ :  ចឹងពីមុនមកដល់ឥឡូវពូបានទៅលេងស្រុកកំណើតបានប៉ុន្មានដង?

សារិន :  រាប់ភ្លេចហើយ ។

វណ្ណៈ  ច្រើនដងហើយ?

សារិនៈ   ដូចជាញឹកណាស់  ជួនអីក្នុងមួយឆ្នាំពីរដងក៏មានដែរ ។

វណ្ណៈ  :  ពូគិតថាទៅថ្ងៃអនាគតកូនចៅគ្រួសារពូមានបំណងរស់នៅក្នុងស្រុកម៉ាឡេរហូតឬមានបំណងទៅរស់នៅខាងស្រុកកំណើតវិញ?

សារិន  :  នៅហ្នឹងរហូតហើយ  ខ្ញុំបានចែកដីធ្លីឲ្យកូននៅទីនេះហើយ  ខ្ញុំមានកូនរៀបការចង់អស់ហើយ ។

វណ្ណៈ  :  បាទ ។

សារិន  :ចែកដីឲ្យមួយកន្លែងៗទៅ  ព្រោះដីនៅស្រុកនោះវាតិចពេក  ខ្ញុំទៅលេងមើលទៅវាពិបាកទុកឲ្យបងប្អូននៅហ្នឹងតែម្តងទៅ ។

វណ្ណៈ:   បាទ ។

សារិនៈ   ខ្ញុំនៅទីនេះមានដីធំទូលាយ  អាចចែកកូនហើយរស់នៅជាមួយកូនតែម្តងទៅ  មានអីៗមួយចប់ហើយនៅនេះ«អ្នកនៅជិតនិយាយថា  កាលវ៉ៃព្រះវិហារហ្នឹងអ្នកខ្មែរក្រហមនៅនេះជាប់គេមិនសុខចិត្តនៅក្នុងទេ»សារិននិយាយត  ចឹងកាលវ៉ៃលើកមុនដ្បើលមួយឈុលហ្នឹងមានណាពួកខ្ញុំនាំគ្នាទៅណា  ខ្លះគេអ្នកមានៗគេទៅ  គេរត់ព្រាតអស់ខ្ញុំអត់ទេនៅហ្នឹង  ខ្ញុំមិនទៅទេផ្ទះខ្ញុំនៅនេះមិនទៅទេ  ដៃទទេមែនតែមិនទៅទេ ។

វណ្ណៈ:   ចឹងបើសិនជាឲ្យកាំភ្លើងវ៉ៃទៀត?

សារិនៈ   ឲ្យសាកមើលដាក់ឥឡូវហ្នឹង  កុំរករឿងខ្ញុំមុនណាស់  ខ្ញុំហាមឲ្យហើយខ្ញុំមិនចង់រំលោភគេទេ  តែគេរំលោភខ្ញុំមិនបានទេ  និយាយមុនហើយចឹងតែម្តងឲ្យតែគោរពសិទ្ធគ្នាទៅវិញទៅមកមិនអីទេ ចឹងបានអាទាហានរាល់ថ្ងៃនេះមកវាមកលេងអីហ្នឹង  ថាឥឡូវយើងសាមគ្គីគ្នាទៅខ្ញុំថាមកពីលោកឯងតើ ។

វណ្ណៈ:   ទាហានថៃមកនិយាយដែរ?

សារិនៈ   បាទ!សំខាន់ខាងលោកឯងហ្នឹងទេ ។

វណ្ណៈ  :  ចឹងទាហានថៃនៅជិតៗនេះទេចឹង?

សារិន  :  បាទ!ទាហានថៃនៅជិតនេះយើងចេញទៅជួបវាហើយ ។

វណ្ណៈ  :  ជួបហើយវានិយាយថាយ៉ាងម៉េចទេ?

សារិន  :  វាថាចឹងយើងសាមគ្គីគ្នាទៅ  រឿងគេៗទៅយើងកុំឈ្លួសគ្នា ។

វណ្ណៈ  :  ចឹងពូមានចេះថៃដែលនិយាយលេងជាមួយវាហ្នឹង?

សារិន  :  ចេះខ្លះៗដែរ  ខ្ញុំថាសំខាន់រឿងលោកឯងតើ  លោកឯងកុំរករឿងខ្ញុំ  តែរករឿងខ្ញុំមិនបានដែរ ថៃខ្លះក៏មានចេះខ្មែរដែរ ។

វណ្ណៈ ចឹងមិនចង់វៃគ្នាទេ សាមគ្គីគ្នាទៅ?

សារិនៈ មិនចង់វៃគ្នាទេ ខ្ញុំខ្លាចតែគាត់វិញទេ បើកុំរករឿងមិនអីទេ ។

វណ្ណៈ ពួកយើងចង់សុខដែរ?

សារិនៈ បាទ ។

វណ្ណៈ មិនចង់វៃគ្នាសង្គ្រាមវាខូចខាត?

សារិនៈ បាទ!វាប៉ះពាល់ហើយខូចខាតដល់ប្រជាពលរដ្ឋផង ម្យ៉ាងយើងវាខាតតែម្តង ។

វណ្ណៈ បាទ ។

សារិនៈ ចឹងបានជាយើងចង់សាមគ្គីជាមួយគ្នាទៅវាចង់សាមគ្គីជាមួយយើងវាមកវានិយាយថាយើងកុំឈ្លោះគ្នាអី ។

វណ្ណៈ ៖ ចឹងខ្ញុំចង់សួរទាក់ទងទៅបញ្ហាវត្តអារាមមានប្រជាជនទៅធ្វើបុណ្យធម្មតាមិនប្រកាន់ថាដូចជំនាន់ខ្មែរក្រហមថា កុំធ្វើបុណ្យជាមួយលោកសង្ឃនៅចាំតែហូបចាំតែទទួលផលចឹងនៅមានគំនិតបែបហ្នឹងទេ?

សារិន ៖ អត់មានគំនិតចឹងទេ អត់រលឹងមានតែនាំគ្នាដាក់វេនទៀតផង មានមនុស្សទៅពេញហៀរ ។

វណ្ណៈ ចឹង?

សារិនៈ បាទ!ដាក់វេនស្រួលបួលណាស់ខែភ្ជុំបិណ្យអីហ្នឹងមានដាក់វេនតែម្តង ឥឡូវនាំគ្នាកសាងឡើងរីកចំរើនកសាងលឿនដែលហ្នឹង ។

វណ្ណៈ ៖ ក្នុងមួយវត្តមានលោកសង្ឃប៉ុន្មានអង្គ?

សារិន ៖ មាន៧អង្គ កាលមុនជាង១០អង្គ តែវត្តបឹងបេងមិនដឹងជាប៉ុន្មានខ្ញុំមិនបានទៅផង ខ្ញុំទៅតែវត្តភ្នំរូង ។

វណ្ណៈ ៖ ចឹងនៅក្នុងសម័យខ្មែរក្រហមពូធ្លាប់ឆ្លងកាត់តែពូមិនបានជួបការហូបចុកលំបាកវេទនាទេកាលជំនាន់ហ្នឹង?

សារិន ៖ បាទ! ការហូបចុកពិបាកកាលឆ្នាំ១៩៧៩ ពេលរត់យួនហ្នឹងទេ ក្រោពីនោះមកទៀតមិនអីទេ ។

វណ្ណៈ ចឹងពិបាកនៅពេលរត់៧៩?

សារិនៈ ពិបាក៧៩ហ្នឹងពិបាកណាស់កាលហ្នឹង ។

វណ្ណៈ ៖ ពូដូចថាខ្ញុំសួរទាក់ទងហ្នឹង ពូគិតថានៅក្នុងសម័យខ្មែរក្រហមហ្នឹងជាសម័យមួយយ៉ាងម៉េចដែរពូគិតថារាល់ការកំហុសឆ្គងហ្នឹង តើថ្នាក់លើជាអ្នកទទួលកំហុសឬមួយយ៉ាងម៉េច តាមគំនិតរបស់ពូ?

សារិន ៖ ខ្ញុំគិតថាជាកំហុសរបស់ថ្នាក់លើ ព្រោះថ្នាក់លើជាអ្នកបញ្ជា ហ្នឹងបើតាមខ្ញុំមើល ។

វណ្ណៈ ៖ បាទ ។

សារិន ៖ ព្រោះអ្នកខាងក្រោមហ្នឹងមិនបានដឹងទេ ខាងលើដាក់យ៉ាងម៉េចខាងក្រោមចេះតែទៅហើយ ។

វណ្ណៈ ៖ បាទ ។

សារិន ៖ នេះតាមខ្ញុំគិត ។

វណ្ណៈ ៖ ចឹងពូគិតថាថ្នាក់ក្រោមធ្វើដោយចិត្តខ្លួនឯងទេ សុទ្ធតែមានគោលការណ៍បញ្ជា?

សារិន ៖ ធ្វើខ្លួនឯងម៉េចនឹងហ៊ានទៅ ។

វណ្ណៈ ៖ ចឹងដូចជាសម័យឥឡូវបើថ្នាក់លើមិនបញ្ជាមកតាមភូមិឃុំមិនហ៊ានធ្វើដែរ?

សារិន ៖ បាទ! ដូចខាងហ្នឹងចឹងមុនមកសម្ភាសន៍ទាល់ជួបនោះសិនបានប្រាប់មកខ្ញុំ ។

វណ្ណៈ ៖ បាទ!ទាល់តែមេបញ្ជាមក បានមកជួបស្រុកខេត្តភូមិទាំងអស់?

សារិន ៖ បាទ! គេហៅថាតាមរចនាសម្ព័ពចឹងទៅ ។

វណ្ណៈ ៖ ចឹងពូជឿថាក្នុងជំនាន់ខ្មែរក្រហមក៏ចឹងដែរ?

សារិនៈ បាទ ។

វណ្ណៈ មិនមែនអ្នកនេះចេះតែកាប់អ្នកនោះបានទេ?

សារិន ៖ អត់បានទេ ។

វណ្ណៈ ៖ ចឹងពូមកដល់ឥឡូវពូគិតថាកូនកម្មាភិបាលថ្នាក់តូចថ្នាក់ធំក៏ដោយនិងប្រជាជនសាមញ្ញាដែល មិនមែនជាកូនកម្មាភិបាល តើពូមានគំនិតមួយឲ្យអ្នកទាំងអស់ហ្នឹងស្រុះស្រួលគ្នាកុំឲ្យមានការបែងចែកវណ្ណៈ តើពូមានគំនិតបែបហ្នឹងទេ គឺចង់ឲ្យមានគំនិតផ្សះផ្សាគ្នាមិនឲ្យមានការបែកចែកខ្មែរក្នុងខ្មែរក្រៅអី?

សារិន ៖ គំនិតរបស់ខ្ញុំចង់ឲ្យមានការផ្សះផ្សារគ្នាឲ្យបានល្អ ។

វណ្ណៈ៖ ចឹងចង់ឲ្យមានគំនិតផ្សះផ្សា?

សារិនៈ បាទ!ឲ្យបានល្អ ។

វណ្ណៈ៖ កុំប្រកាន់ថាអ្នកនេះចេះអ្នកនោះចុះ?

សារិនៈ កុំប្រកាន់ថាអ្នកនេះខ្មែរខៀវអ្នកនេះខ្មែរស ខ្មែរក្រហមអីណាស់ ។

វណ្ណៈ៖ បាទ ។

សារិនៈ ខ្ញុំចង់ឲ្យមានខ្មែរតែមួយតែម្តង ។

វណ្ណៈ ៖ ពូគិតថាតុលាការធ្វើឲ្យមានផលប៉ះពាល់អីខ្លះដែលឬមានផលចំណេញអ្វីខ្លះដែរ?

សារិន ៖ អាហ្នឹងមិនដឹងជាយ៉ាងម៉េចទេ ។

វណ្ណៈ ៖ ពូគិតថាតុលាការជាវិធីល្អសម្រាប់ឲ្យដឹងខុសត្រូវឬអាចជួយរកយុត្តិធម៌និងផ្លូវផ្សះផ្សាទេ?

សារិន ៖ បាទ ។

វណ្ណៈ ៖ ចឹងពូគិតថាមានតុលាការល្អទេ?

សារិន ៖ ល្អហើយដើម្បីរកយុត្តិធម៌ឲ្យយើងគ្រប់គ្នា ។

វណ្ណៈ៖ បាទ ។

សារិនៈ ព្រោះអ្នកខ្លះខុស ។

វណ្ណៈ៖ បាទ ។

សារិនៈ បើខុសហើយមិនតុលាការដោះស្រាយតុលាការវិនិច្ឆ័យខុសត្រូវទេ នៅតែខុសរហូតចឹងក៏មិនកើតដែរ?

វណ្ណៈ៖ បាទ ។

សារិនៈ ទាល់តែរកអ្នកខុសឃើញបានឃើញអ្នកល្អ ។

វណ្ណៈ ៖ ចឹងពូដូចជាខ្ញុំគ្មានអីបន្ថែមទៀតទេ តើពូមានចង់និយាយអ៊ីបន្ថែមទៀតទេ?

សារិន ៖ ខ្ញុំអត់មានទេ ។

វណ្ណៈ ៖ ចឹងខ្ញុំអរគុណពូច្រើនហើយ ។

សារិន ៖ បាទ ។

**«ចប់»**